ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០១ កយ.សសរ/២៥

# សេចក្ដីសម្រេច

## ស្ដីពី

## ការកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធ
## នៃគណៈកម្មការទទួលបន្ទុកដឹកនាំរៀបចំ
## ការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
## និងវិស័យរដ្ឋប្បវេណី

២០២៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០១ កយ.សសរ/២៥

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធនៃគណៈកម្មការទទួលបន្ទុកដឹកនាំរៀបចំការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសម្រេចលេខ ២៣ កយ.សសរ/២៤ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុកដឹកនាំរៀបចំការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

សេចក្តីសម្រេចនេះ កំណត់អំពីការកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធ នៃគណៈកម្មការទទួលបន្ទុកដឹកនាំរៀបចំការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី (គ.វ.ព.រ.)។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ប្រការ២ ..**

សមាសភាពនៃ គ.វ.ព.វ. ត្រូវបានកែសម្រួល ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ើត រិទ្ធ** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ជិន ម៉ាលីន** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ជីវ សុខហាក់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥-ឯកឧត្តម | **សួន វិសាល** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦-ឯកឧត្តម | **ញាន វណ្ណៈ** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ | អនុប្រធាន |
| ៧-ឯកឧត្តម | **តាន់ហ៊ាង ដាវ័ណ្ណ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៨-ឯកឧត្តម | **សេង ឌីណា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៩-ឯកឧត្តម | **សេង ប៊ុនឃាង** | សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | អនុប្រធាន |
| ១០-ឯកឧត្តម | **យូ ប៊ុនឡេង** | អនុប្រធានតុលាការកំពូល | អនុប្រធាន |
| ១១-ឯកឧត្តម | **តាំង ស៊ុនឡាយ** | អនុប្រធានតុលាការកំពូល | អនុប្រធាន |
| ១២-ឯកឧត្តម | **អ៊ុក គឹមសិទ្ធិ** | អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល | អនុប្រធាន |
| ១៣-ឯកឧត្តម | **សេង នាង** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៤-ឯកឧត្តម | **គង់ តារាឆាត** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៥-លោកជំទាវ | **ចាំង ស៊ីណាត** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៦-លោកជំទាវ | **សែម សក្តិភូឡា** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៧-ឯកឧត្តម | **ច័ន្ទ រង្សី** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៨-ឯកឧត្តម | **ម្លប់ សំណាង** | ចៅក្រមតុលាការកំពូល | សមាជិក |
| ១៩-ឯកឧត្តម | **ចាយ ច័ន្ទតារាវណ្ណ** | ចៅក្រមតុលាការកំពូល | សមាជិក |
| ២០-ឯកឧត្តម | **សេង ស៊ីវុត្ថា** | ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| ២១-ឯកឧត្តម | **ម៉ុង មុនីចរិយា** | ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ | សមាជិក |
| ២២-ឯកឧត្តម | **សម ប៊ុនថុន** | ប្រធានសាលាឧទ្ធរណ៍បាត់ដំបង | សមាជិក |
| ២៣-ឯកឧត្តម | **សុខ កល្យាណ** | ប្រធានសាលាឧទ្ធរណ៍ព្រះសីហនុ | សមាជិក |
| ២៤-ឯកឧត្តម | **អ៊ុក សាវុធ** | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| ២៥-ឯកឧត្តម | **ហួត វុទ្ធី** | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ | សមាជិក |
| ២៦-ឯកឧត្តម | **ឡួន សាន** | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាត់ដំបង | សមាជិក |
| ២៧-ឯកឧត្តម | **សរ យសថាវរៈ** | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ព្រះសីហនុ | សមាជិក |
| ២៨-ឯកឧត្តម | **ផូង សំគី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | សមាជិក |

| | | | |
|---|---|---|---|
| ២៩-ឯកឧត្តម | **យ៉ម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក<br>នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | សមាជិក |
| ៣០-លោកជំទាវ | **សុន សុខាលីដា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក<br>នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៣១-ឯកឧត្តម | **ខាត់ ឆវ័ន្ត** | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ | សមាជិក។ |

គ.វ.ព.រ. មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំការងារធ្វើសេចក្តីព្រាងវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តការងារធ្វើសេចក្តីព្រាងវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី
- បំពេញការងារផ្សេងទៀត ដើម្បីធានាឱ្យការអនុវត្តការងារធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី ប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។

**ប្រការ៣ .-**

គ.វ.ព.រ. មានក្រុមការងារបច្ចេកទេសចំនួន ៤ ជាសេនាធិការ ទទួលបន្ទុកលើការងារសិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ការធ្វើវិសោធនកម្មក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី រួមមាន៖

- ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ
- ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី
- ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី។

**ប្រការ៤ .-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **កើត សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | សហប្រធាន |
| ២-ឯកឧត្តម | **ម៉ុង មុនីចរិយា** | ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ | សហប្រធាន |
| ៣-ឯកឧត្តម | **អ៊ុក គឹមសិទ្ធិ** | អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល | អនុប្រធាន |
| ៤-ឯកឧត្តម | **ច័ន្ទ រង្សី** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៥-ឯកឧត្តម | **ចាយ ច័ន្ទតារាវណ្ណា** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៦-ឯកឧត្តម | **សម ប៊ុនថុន** | ប្រធានសាលាឧទ្ធរណ៍បាត់ដំបង | អនុប្រធាន |
| ៧-លោកជំទាវ | **សុខ ឆវ័ន្ត** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៨-ឯកឧត្តម | **ផូង សំភី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃ<br>អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | អនុប្រធាន |
| ៩-លោកជំទាវ | **សុន សុខាលីដា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក<br>នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | អនុប្រធានប្រចាំការ |
| ១០-ឯកឧត្តម | **ច្រឹង ខ្មៅ** | ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |

| | | | |
|---|---|---|---|
| ១១-ឯកឧត្តម | **កែវ សុជាតិ** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបាត់ដំបង | សមាជិក |
| ១២-ឯកឧត្តម | **វង្ស ម៉ុនវិសុទ្ធ** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម | សមាជិក |
| ១៣-ឯកឧត្តម | **ឡាយ លាងសេង** | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ | សមាជិក |
| ១៤-លោកជំទាវ | **គា ម៉ុម៉ី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ | សមាជិក |
| ១៥-ឯកឧត្តម | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៦-លោក | **អៀម សំណាង** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៧-លោក | **អាត ច័ន្ទតារា** | ចៅក្រមសាលាដំបូងខេត្តកណ្តាល | សមាជិក |
| ១៨-លោក | **សេង រិទ្ធី** | ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ | សមាជិក |
| ១៩-លោក | **ម្លង់ សុផល** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ២០-លោក | **ម៉េង ម៉េងគ័ង** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ២១-លោក | **ឈុន សីហា** | អនុប្រធាននាយកដ្ឋាន | លេខាធិការ |
| ២២-លោក | **ជូ ទីឡេង** | អនុប្រធាននាយកដ្ឋាន | លេខាធិការ។ |

ក្រុមការងារបច្ចេកទេសនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ រួមទាំងកំណត់បញ្ហាប្រឈម និងភាពខ្វះចន្លោះនានា ដែលជាមូលដ្ឋានក្នុងការរៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ សំដៅធានានូវប្រសិទ្ធភាពនៃការអនុវត្តស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គមកម្ពុជា និងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ និងសម្រេច
- សិក្សា និងស្រាវជ្រាវអំពីនីតិវិធីព្រហ្មទណ្ឌនៅតាមបណ្តាប្រទេសនានា
- ពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីប្រមូលធាតុចូលសំខាន់ៗលើសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន គវ.ព.វ. លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានាពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ
- រៀបចំកិច្ចប្រជុំ កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍បូកសរុប សម្រាប់ការរៀបចំ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពការងាររៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ
- ចូលរួមការពារសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌនៅក្នុងកិច្ចប្រជុំពាក់ព័ន្ធនានា
- អនុវត្តការកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៥ .-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សេខ ឌីណា** | រដ្ឋលេខាធិការ | សហប្រធាន |
| ២-ឯកឧត្តម | **ផូច សំគី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | សហប្រធាន |
| ៣-លោកជំទាវ | **សែម សក្តិភូឡា** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៤-ឯកឧត្តម | **ហ្សូត ឧុទ្ធី** | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ | អនុប្រធាន |
| ៥-ឯកឧត្តម | **ទឹម ស៊ីផា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៦-លោកជំទាវ | **សុន សុខាលីដា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | អនុប្រធានប្រចាំការ |
| ៧-ឯកឧត្តម | **លាវ ស្រេង** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្តាល | សមាជិក |
| ៨-ឯកឧត្តម | **ខត្យ ម៉ីនវិសុទ្ធ** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម | សមាជិក |
| ៩-ឯកឧត្តម | **ចិន ឧុត្តា** | នាយករងខុទ្ទកាល័យ | សមាជិក |
| ១០-ឯកឧត្តម | **ឆុប សុធនវិសុទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន កិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ១១-លោកជំទាវ | **សុខ វិសាល** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២-លោកជំទាវ | **ប៉ែន ផល្លីការ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣-លោក | **ម៉ុខ មុនីសោភា** | ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង | សមាជិក |
| ១៤-លោក | **ពេជ្រ វិជ្ជាធរ** | អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ | សមាជិក |
| ១៥-លោក | **សាន ម៉ីនឡើន** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១៦-លោក | **ឆាយ ហុង** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១៧-លោក | **សំម ឫទ្ធីវាសនា** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១៨-លោក | **គួច ឧត្តម** | ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម | សមាជិក |
| ១៩-លោក | **ឌុធ សាវី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២០-លោក | **ឌី រីដា** | អនុប្រធាននាយកដ្ឋាន | លេខាធិការ |
| ២១-លោក | **សុទ្ធ ម៉ូលីណា** | អនុប្រធាននាយកដ្ឋាន | លេខាធិការ។ |

ក្រុមការងារបច្ចេកទេសនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តក្រមព្រហ្មទណ្ឌ រួមទាំងកំណត់បញ្ហាប្រឈម និងភាពខ្វះចន្លោះនានា ដែលជាមូលដ្ឋានក្នុងការរៀបចំការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ សំដៅធានានូវប្រសិទ្ធភាពនៃការអនុវត្តស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គមកម្ពុជា និងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល

- រៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ និងសម្រេច
- សិក្សា និងស្រាវជ្រាវអំពីច្បាប់ព្រហ្មទណ្ឌនៅតាមបណ្តាប្រទេសនានា
- ពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីប្រមូលធាតុចូលសំខាន់ៗលើសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន គ.វ.ព.វ. លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានាពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ
- រៀបចំកិច្ចប្រជុំ កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍បូកសរុប សម្រាប់ការរៀបចំ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពការងាររៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំដើម្បីដាក់ជូន គ.វ.ព.វ. ពិនិត្យ
- ចូលរួមការពារសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌនៅក្នុងកិច្ចប្រជុំពាក់ព័ន្ធនានា
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៦ .-**

ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ញាន ថណ្ណៈ** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ | សហប្រធាន |
| ២-ឯកឧត្តម | **តាំង ស៊ុនឡាយ** | អនុប្រធានតុលាការកំពូល | សហប្រធាន |
| ៣-ឯកឧត្តម | **យឹម សារី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **សេង នាង** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៥-ឯកឧត្តម | **ប្លង់ សំណាង** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៦-ឯកឧត្តម | **លី តៃសេង** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម | **ឌី សុខ** | ប្រធានសាលាដំបូងខេត្តកណ្តាល | សមាជិក |
| ៨-ឯកឧត្តម | **តុប ឈុនហេង** | ប្រធានសាលាដំបូងខេត្តក្រចេះ | សមាជិក |
| ៩-ឯកឧត្តម | **ហេង សុខណា** | នាយកសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា | សមាជិក |
| ១០-ឯកឧត្តម | **ខាំ សុមករា** | នាយកសាលាភូមិន្ទអាជ្ញាសាលា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា | សមាជិក |
| ១១-លោក | **លាង រិទ្ធី** | ចៅក្រមសាលាឧទ្ធរណ៍ត្បូងឃ្មុំ | សមាជិក |
| ១២-លោក | **ស សំណាង** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១៣-លោក | **ញឹម ពិសាល** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ១៤-លោក | **ធន់ ដារិទ្ធ** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |

| | | | |
|---|---|---|---|
| ១៥-លោក | **ឈាង ឈុន** | ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ | សមាជិក |
| ១៦-លោក | **ឡៅ ត្រឹម** | ចៅក្រមសាលាដំបូងខេត្តកោះកុង | សមាជិក |
| ១៧-លោក | **យ៉ែម តុលា** | ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ | សមាជិក |
| ១៨-លោក | **ឈឿន គុយអេង** | សមាជិកខុទ្ទកាល័យ | លេខាធិការ |
| ១៩-កញ្ញា | **គន្ធា ស្រីសុជាតា** | សមាជិកខុទ្ទកាល័យ | លេខាធិការ |
| ២០-កញ្ញា | **គង់ ស្រីពេជ្រ** | សមាជិកខុទ្ទកាល័យ | លេខាធិការ។ |

ក្រុមការងារបច្ចេកទេសនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី រួមទាំងកំណត់បញ្ហាប្រឈម និងភាពខ្វះចន្លោះនានា ដែលជាមូលដ្ឋានក្នុងការរៀបចំការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី សំដៅធានានូវប្រសិទ្ធភាពនៃការអនុវត្តស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គមកម្ពុជា និងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ និងសម្រេច
- សិក្សា និងស្រាវជ្រាវអំពីច្បាប់នីតិវិធីរដ្ឋប្បវេណីនៅតាមបណ្តាប្រទេសនានា
- ពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលសំខាន់ៗលើសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន គ.វ.ព.រ. លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានា ពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី
- រៀបចំកិច្ចប្រជុំ កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍បូកសរុប សម្រាប់ការរៀបចំ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពការងាររៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណីដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំ ដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ
- ចូលរួមការពារសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណីនៅក្នុងកិច្ចប្រជុំពាក់ព័ន្ធនានា
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៧ ._**

ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **តាន់ហ៊ាង ដាវ័ណ្ណា** | រដ្ឋលេខាធិការ | សហប្រធាន |
| ២-លោកជំទាវ | **ចាំង ស៊ីណាត** | ចៅក្រមតុលាការកំពូល | សហប្រធាន |
| ៣-ឯកឧត្តម | **គង់ តារាណាត** | ចៅក្រមតុលាការកំពូល | អនុប្រធាន |
| ៤-លោកជំទាវ | **ម៉ៅ តិរុណា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥-លោកជំទាវ | **អ៊ុំ រីណា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៦-ឯកឧត្តម | **យ៉ម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | អនុប្រធានប្រចាំការ |
| ៧-ឯកឧត្តម | **អ៊ិន វ៉ានវិបុល** | អនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| ៨-ឯកឧត្តម | **ខ្ចួន ណារ៉ា** | ប្រធានសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ៩-ឯកឧត្តម | **ហេង ឆាយ** | សមាជិកក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ១០-ឯកឧត្តម | **សុខ ហ៊ី** | សមាជិកក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ១១-លោកជំទាវ | **ម៉ីយ ធីតា** | សមាជិកក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ១២-លោក | **សេង សត្យា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | សមាជិក |
| ១៣-លោក | **គី ខេមលីន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ | សមាជិក |
| ១៤-លោក | **ម៉ុង មុនីសោភា** | ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង | សមាជិក |
| ១៥-លោកស្រី | **សែម សែងទេថៃ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៦-លោក | **ភាន់ សុទ្ធប៉ូលីន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៧-លោក | **សូ សុខហុង** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៨-លោកស្រី | **អ៊ុក សិរី** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ១៩-លោក | **ថាំង សុខលីម** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ២០-លោក | **ជីវ កុកពេន** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ២១-លោក | **ឈៀវ គីមហាក់** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ២២-លោក | **កែវ វ៉ាន្នី** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ២៣-លោក | **កែវ លីគង់** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ២៤-លោកស្រី | **មិន្ទស៊ុំ សូលីដា** | អនុប្រធាននាយកដ្ឋាន | លេខាធិការ |
| ២៥-លោក | **វង្សគីមសាន្ត** | អនុប្រធាននាយកដ្ឋាន | លេខាធិការ |
| ២៦-លោក | **អេង សំណាង** | អនុប្រធាននាយកដ្ឋាន | លេខាធិការ។ |

ក្រុមការងារបច្ចេកទេសនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តក្រមរដ្ឋប្បវេណី រួមទាំងកំណត់បញ្ហាប្រឈម និងភាពខ្វះចន្លោះនានា ដែលជាមូលដ្ឋានក្នុងការរៀបចំការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី សំដៅធានានូវប្រសិទ្ធភាពនៃការអនុវត្តស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គមកម្ពុជា និងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ និងសម្រេច

- សិក្សា និងស្រាវជ្រាវអំពីច្បាប់រដ្ឋប្បវេណីនៅតាមបណ្តាប្រទេសនានា
- ពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលសំខាន់ៗលើសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន គ.វ.ព.រ. លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានា ពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី
- រៀបចំកិច្ចប្រជុំ កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍បូកសរុប សម្រាប់ការរៀបចំ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពការងាររៀបចំសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំ ដើម្បីដាក់ជូន គ.វ.ព.រ. ពិនិត្យ
- ចូលរួមការពារសេចក្តីព្រាងច្បាប់សម្រាប់ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីនៅក្នុងកិច្ចប្រជុំពាក់ព័ន្ធនានា
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ